# គម្រោង Medicare Advantage និងផ្នែក D

## ឆ្នាំគម្រោង៖ ថ្ងៃទី 1 ខែមករា ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023

## រដ្ឋ California

ខោន Los Angeles, Santa Clara

**Anthem MediBlue Full Dual Advantage (HMO D-SNP)**

Y0114_23_3002534_U_M_KH_0108 Accepted
H4161-001-000_CA_HMO DE-SNP

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

## សេចក្តីផ្តើម

ឯកសារនេះគឺជាការសង្ខេបខ្លីៗអំពីអត្ថប្រយោជន៍ និងសេវាដែលរ៉ាប់រងដោយ Anthem MediBlue Full Dual Advantage (HMO D-SNP)។ វារួមបញ្ចូលទាំងចម្លើយសម្រាប់សំណួរដែលគេសួរញឹកញាប់ ព័ត៌មានទំនាក់ទំនងសំខាន់ៗ ទិដ្ឋភាពទូទៅនៃអត្ថប្រយោជន៍ និងសេវាកម្មដែលផ្តល់ជូន និងព័ត៌មានអំពីសិទ្ធិរបស់អ្នកជាសមាជិកនៃAnthem MediBlue Full Dual Advantage (HMO D-SNP)។ ពាក្យគន្លឹះនិងនិយមន័យមានតាមលំដាប់អក្ខរក្រមក្នុងជំពូកចុងក្រោយនៃ *សៀវភៅណែនាំសមាជិក*។

## តារាងមាតិកា


A. ការបដិសេធ ........ 2

B. សំណួរដែលគេសួរញឹកញាប់ (FAQ) ........ 3

C. បញ្ជីសេវាដែលបានធានារ៉ាប់រង ........ 8

D. អត្ថប្រយោជន៍ដែលត្រូវបានធានារ៉ាប់រងពីខាងក្រៅគម្រោង Anthem MediBlue Full Dual Advantage (HMO D-SNP) ........ 25

E. សេវាដែល Anthem MediBlue Full Dual Advantage (HMO D-SNP), Medicare និង Medi-Cal មិនធានារ៉ាប់រងលើ ........ 26

F. សិទ្ធិរបស់អ្នកជាសមាជិកនៃគម្រោងនេ ........ 27

G. របៀបនៃការដាក់ពាក្យបណ្តឹងតវ៉ា ឬប្តឹងឧទ្ធរណ៍លើសេវាកម្មដែលបានបដិសេធ ........ 29

H. តើអ្នកត្រូវធ្វើអ្វីប្រសិនបើអ្នកសង្ស័យថាមានការក្លែងបន្លំ ........ 31


Y0114_23_3002534_U_M_KH_0108 1041730MUSKHMUB_0108

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

## A. ការបដិសេធ

នេះគឺជាសេចក្តីសង្ខេបនៃសេវាសុខភាពដែលរ៉ាប់រងដោយ Anthem MediBlue Full Dual Advantage (HMO D-SNP) សម្រាប់ឆ្នាំ 2023។ នេះគ្រាន់តែជាសេចក្តីសង្ខេបប៉ុណ្ណោះ។ សូមអាន *សៀវភៅណែនាំសមាជិក* សម្រាប់បញ្ជីពេញលេញនៃអត្ថប្រយោជន៍។ អ្នកអាច *ទាក់ទង* សេវាសមាជិកតាមរយៈលេខទូរសព្ទដែលបង្ហាញខាងក្រោម ដើម្បីស្នើសុំច្បាប់ចម្លងនៃ *សៀវភៅណែនាំសមាជិករបស់អ្នក។* អ្នកក៏អាចចូលប្រើ *សៀវភៅណែនាំសមាជិករបស់អ្នក* នៅលើគេហទំព័ររបស់គម្រោងដែលបង្ហាញនៅខាងក្រោមទំព័រនេះ។

- Anthem MediBlue Full Dual Advantage (HMO D-SNP) គឺជាគម្រោង HMO D-SNP ជាមួយនឹងកិច្ចសន្យា Medicare និងកិច្ចសន្យាជាមួយកម្មវិធី California Medicaid។ ការចុះឈ្មោះនៅក្នុងគម្រោង Anthem Blue Cross Partnership អាស្រ័យលើការបន្តកិច្ចសន្យាជាថ្មី។ Anthem Blue Cross គឺជាឈ្មោះសញ្ញាពាណិជ្ជកម្មសម្រាប់ Blue Cross of California។ Anthem Blue Cross and Blue Cross of California Partnership Plan, Inc. គឺជាអ្នកទទួលអាជ្ញាបណ្ណឯករាជ្យនៃសមាគមន៍ Blue Cross Association។ Anthem គឺជាពាណិជ្ជសញ្ញាដែលបានចុះបញ្ជីរបស់ Anthem Insurance Companies, Inc.។

- សម្រាប់ព័ត៌មានបន្ថែមអំពី **Medicare** អ្នកអាចអានសៀវភៅណែនាំ *និងអ្នក*។ សៀវភៅមានសេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ Medicare សិទ្ធិ និងកិច្ចការពារ និងចម្លើយចំពោះសំណួរដែលគេសួរញឹកញាប់អំពី Medicare។ អ្នកអាចទទួលបានវានៅលើគេហទំព័រ Medicare ([www.medicare.gov](http://www.medicare.gov)) ឬតាមរយៈការទូរសព្ទទៅលេខ 1-800-MEDICARE (1-800-633-4227) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY គួរតែទូរសព្ទទៅកាន់លេខ 1-877-486-2048។ សម្រាប់ព័ត៌មានបន្ថែមអំពី **Medi-Cal** អ្នកអាចពិនិត្យមើលគេហទំព័ររបស់ក្រសួងសេវាថែទាំសុខភាព (DHCS) រដ្ឋ California ([www.dhcs.ca.gov](http://www.dhcs.ca.gov)) ឬទាក់ទងការិយាល័យមន្ត្រីបណ្តឹងសាធារណៈរបស់ Medi-Cal 1-888-452-8609 ពីថ្ងៃចន្ទ រហូតដល់ថ្ងៃសុក្រ ចន្លោះម៉ោង 8:00 ព្រឹក ដល់
5:00 ល្ងាច អ្នកក៏អាចហៅទូរសព្ទទៅការិយាល័យមន្ត្រីបណ្តឹងសាធារណៈ ពិសេសសម្រាប់អ្នកដែលមានទាំង Medicare និង Medi-Cal តាមរយៈលេខ 1-855-501-3077 ពីថ្ងៃចន្ទ រហូតដល់ថ្ងៃសុក្រ ចន្លោះម៉ោង 9:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច។

- អ្នកអាចទទួលបានឯកសារនេះដោយឥតគិតថ្លៃក្នុងឬទម្រង់ផ្សេងៗ ដូចជាអក្សរពុម្ពធំ អក្សរសម្រាប់មនុស្សពិការភ្នែក ឬជាសំឡេង។ ទូរសព្ទទៅលេខ **1-833-707-3129** (TTY: **711**) ពីម៉ោង 8 ព្រឹក ដល់ ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងតែថ្ងៃបុណ្យ លែងអំណរគុណ និងបុណ្យណូអែល) ចាប់ពីថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែមីនា និងថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (លើកលែងតែថ្ងៃឈប់សម្រាក) ចាប់ពីថ្ងៃទី 1 ខែមេសា ដល់ថ្ងៃទី 30 ខែកញ្ញា។ ការហៅទៅលេខនេះគឺឥតគិតថ្លៃ។

- អ្នកអាចទទួលបានឯកសារនេះដោយឥតគិតថ្លៃតាមទម្រង់ និងភាសាផ្សេងៗ ដូចជាបោះពុម្ពខ្នាតធំ អក្សរសម្រាប់មនុស្សពិការភ្នែក និងជាទិន្នន័យ និងជា CD សំឡេង។ ទូរសព្ទទៅកាន់សេវាសមាជិកតាមលេខដែលបង្ហាញនៅផ្នែកខាងក្រោមនៃទំព័រ។ នៅពេលហៅទូរសព្ទ សូមប្រាប់យើងខ្ញុំប្រសិនបើអ្នកចង់ដាក់វាជាសំណើជាប្រចាំ។ នោះមានន័យថា យើងនឹងផ្ញើឯកសារដូចគ្នាទៅតាមទម្រង់ និងភាសាដែលអ្នកបានស្នើសុំជារៀងរាល់ឆ្នាំ។ អ្នកក៏អាចហៅទូរសព្ទមកយើងខ្ញុំដើម្បីផ្លាស់ប្តូរ ឬបញ្ឈប់សំណើរជាប្រចាំផងដែរ។ អ្នកក៏អាចស្វែងរកឯកសាររបស់អ្នកលើអ៊ីនធឺណិតនៅលើគេហទំព័រនៅផ្នែកខាងក្រោមនៃទំព័រនេះ។

## B. សំណួរដែលគេសួរញឹកញាប់ (FAQ)

តារាងខាងក្រោមបង្ហាញសំណួរដែលគេសួរញឹកញាប់។

| សំណួរដែលគេសួរញឹកញាប់ | ចម្លើយ |
|---|---|
| **តើគម្រោងសម្របសម្រួល Medicare-Medi-Cal គឺជាអ្វី?** | គម្រោងសម្របសម្រួល Medicare-Medi-Calគឺជាគម្រោងសុខភាពដែលមានកិច្ចសន្យាជាមួយទាំង Medicare និង Medi-Cal ដើម្បីផ្តល់អត្ថប្រយោជន៍ពីកម្មវិធីទាំងពីរនេះដល់អ្នកចុះឈ្មោះ។ វាគឺសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ។ គម្រោងសម្របសម្រួល Medicare-Medi-Cal គឺអង្គការចាត់តាំងមួយដែលបង្កើតដោយមានវេជ្ជបណ្ឌិត មន្ទីរពេទ្យ ឱសថស្ថាន អ្នកផ្តល់សេវា និងការគាំទ្ររយៈពេលវែង (LTSS) និងអ្នកផ្តល់សេវាផ្សេងៗ។ វាថែមទាំងមានអ្នកសម្របសម្រួលការថែទាំដើម្បីជួយអ្នកក្នុងការគ្រប់គ្រងលើអ្នកផ្តល់សេវា និងសេវាកម្ម |
| **តើខ្ញុំនឹងទទួលបានអត្ថប្រយោជន៍ Medicare និង Medi-Cal ដូចគ្នានៅក្នុង Anthem MediBlue Full Dual Advantage (HMO D-SNP) ដែលខ្ញុំទទួលបានឥឡូវនេះដែរឬទេ?**<br>(បន្តនៅទំព័របន្ទាប់) | អ្នកនឹងទទួលបានអត្ថប្រយោជន៍ភាគច្រើននៃ Medicare និង Medi-Cal ដែលរ៉ាប់រងរបស់អ្នកដោយផ្ទាល់ពី Anthem MediBlue Full Dual Advantage (HMO D-SNP)។ អ្នកនឹងធ្វើការជាមួយក្រុមអ្នកផ្តល់សេវាដែលនឹងជួយកំណត់ថាតើសេវាកម្មបែបណាដែលល្អបំផុតសមនឹងតម្រូវការផ្សេងៗរបស់អ្នក។ នេះមានន័យថាសេវាកម្មមួយចំនួនដែលអ្នកទទួលបានឥឡូវនេះអាចផ្លាស់ប្តូរដោយផ្អែកលើតម្រូវការរបស់អ្នក និងការវាយតម្លៃរបស់វេជ្ជបណ្ឌិត និងក្រុមថែទាំរបស់អ្នក។ អ្នកក៏អាចទទួលបានអត្ថប្រយោជន៍ផ្សេងទៀតក្រៅពីគម្រោងសុខភាពរបស់អ្នកតាមរបៀបដែលអ្នកធ្វើឥឡូវនេះ ដោយផ្ទាល់ពីទីភ្នាក់ងាររដ្ឋ ឬស្រុកដូចជាសេវាជំនួយក្នុងផ្ទះ (IHSS) សេវាសុខភាពផ្លូវចិត្តពិសេស និងបញ្ហាការប្រើប្រាស់សារធាតុញៀន ឬសេវាមជ្ឈមណ្ឌលក្នុងតំបន់។<br><br>នៅពេលអ្នកចុះឈ្មោះចូលក្នុង Anthem MediBlue Full Dual Advantage (HMO D-SNP) អ្នក និងក្រុមថែទាំរបស់អ្នកនឹងធ្វើការរួមគ្នាដើម្បីបង្កើតគម្រោងថែទាំផាលក្ខណៈបុគ្គលដើម្បីដោះស្រាយតម្រូវការសុខភាព និងការគាំទ្រដែលអ្នកត្រូវការដោយឆ្លុះបញ្ចាំងពីចំណង់ចំណូលចិត្ត និងគោលដៅផ្ទាល់ខ្លួនរបស់អ្នក។<br><br>ប្រសិនបើអ្នកកំពុងប្រើឱសថមានវេជ្ជបញ្ជារបស់ Medicare ផ្នែក D ដែល Anthem MediBlue Full Dual Advantage (HMO D-SNP) ជាធម្មតាមិនរ៉ាប់រងទេនោះ អ្នកអាចទទួលបានការផ្គត់ផ្គង់បណ្តោះអាសន្ន ហើយយើងនឹងជួយអ្នកប្តូរទៅឱសថផ្សេងទៀត |

# Anthem MediBlue Full Dual Advantage (HMO D-SNP) \| សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| សំណួរដែលគេសួរញឹកញាប់ | ចម្លើយ |
|---|---|
| **តើខ្ញុំនឹងទទួលបានអត្ថប្រយោជន៍ Medicare និង Medi-Cal ដូចគ្នានៅក្នុង Anthem MediBlue Full Dual Advantage (HMO D-SNP) ដែលខ្ញុំទទួលបានឥឡូវនេះដែរឬទេ?**<br>(ត) | ឬទទួលបានការលើកលែងពី Anthem MediBlue Full Dual Advantage (HMO D-SNP) ដើម្បីរ៉ាប់រងឱសថរបស់អ្នកប្រសិនបើចាំបាច់ខាងវេជ្ជសាស្ត្រ។ សម្រាប់ព័ត៌មានបន្ថែម សូមហៅទូរសព្ទទៅកាន់សេវាសមាជិកតាមរយៈលេខដែលបង្ហាញនៅផ្នែកខាងក្រោមនៃទំព័រ។ |
| **តើខ្ញុំអាចទៅជួបគ្រូពេទ្យដូចគ្នាដែលខ្ញុំប្រើឥឡូវនេះបានទេ?**<br>(បន្តនៅទំព័របន្ទាប់) | ជាញឹកញាប់វាអាចទៅរួច។ ប្រសិនបើអ្នកផ្តល់សេវារបស់អ្នក (រួមទាំងវេជ្ជបណ្ឌិត មន្ទីរពេទ្យ អ្នកព្យាបាលរោគ ឱសថស្ថាន និងអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀត) ធ្វើការជាមួយ Anthem MediBlue Full Dual Advantage (HMO D-SNP) ហើយមានកិច្ចសន្យាជាមួយយើង អ្នកអាចបន្តទៅរកពួកគេ។<br><br>• អ្នកផ្តល់សេវាដែលមានកិច្ចព្រមព្រៀងជាមួយយើងគឺ "នៅក្នុងបណ្តាញ"។ អ្នកផ្តល់សេវានៅក្នុងបណ្តាញចូលរួមនៅក្នុងគម្រោងរបស់យើង។ នោះមានន័យថា ពួកគេទទួលយកសមាជិកនៃគម្រោងរបស់យើង និងផ្តល់សេវាកម្មគម្រោងរ៉ាប់រងរបស់យើង។ **អ្នកត្រូវតែប្រើអ្នកផ្តល់សេវានៅក្នុងបណ្តាញរបស់ Anthem MediBlue Full Dual Advantage (HMO D-SNP)។** ប្រសិនបើអ្នកប្រើប្រាស់អ្នកផ្តល់សេវា ឬឱសថស្ថានដែលមិនមាននៅក្នុងបណ្តាញរបស់យើង គម្រោងនេះប្រហែលជាមិនបង់ប្រាក់សម្រាប់សេវាកម្ម ឬឱសថទាំងនេះទេ។<br><br>• ប្រសិនបើអ្នកត្រូវការការថែទាំបន្ទាន់ ឬការសង្គ្រោះក្នុងគ្រាអាសន្ន ឬសេវាកម្មលាងតម្រងនោមនៅក្រៅតំបន់សេវានោះ អ្នកអាចប្រើប្រាស់អ្នកផ្តល់សេវាខាងក្រៅពីគម្រោងរបស់ Anthem MediBlue Full Dual Advantage (HMO D-SNP)។<br><br>• ប្រសិនបើអ្នកកំពុងស្ថិតក្រោមការព្យាបាលជាមួយអ្នកផ្តល់សេវាដែលចេញពីបណ្តាញរបស់ Anthem MediBlue Full Dual Advantage (HMO D-SNP) ឬមានទំនាក់ទំនងដែលបានបង្កើតឡើងជាមួយអ្នកផ្តល់សេវា ដែលចេញពីបណ្តាញរបស់ Anthem MediBlue Full Dual Advantage (HMO D-SNP) សូមទូរសព្ទទៅផ្នែកបម្រើសេវាសមាជិក ដើម្បីពិនិត្យមើលអំពីការបន្តភ្ជាប់ទំនាក់ទំនង។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| សំណួរដែលគេសួរញឹកញាប់ | ចម្លើយ |
|---|---|
| **តើខ្ញុំអាចទៅជួបគ្រូពេទ្យដូចគ្នាដែលខ្ញុំប្រើឥឡូវនេះបានទេ?**<br>(ត) | អ្នកអាចបន្តប្រើប្រាស់វេជ្ជបណ្ឌិតដែលអ្នកប្រើប្រាស់ឥឡូវនេះរហូតដល់ 12 ខែសម្រាប់សេវាកម្មដែលរ៉ាប់រងដោយ Medicare និងរហូតដល់ 12 ខែសម្រាប់សេវាកម្មដែលរ៉ាប់រងដោយ Medi-Cal។ អ្នកនឹងត្រូវបានជូនដំណឹងក្នុងរយៈពេល 30 ថ្ងៃតាមប្រតិទិន មុនពេលចុងបញ្ចប់នៃរយៈពេលការបន្តការថែទាំ ដើម្បីប្តូរការថែទាំរបស់អ្នកទៅកាន់អ្នកផ្តល់សេវាក្នុងបណ្តាញ។ ទាក់ទងទៅផ្នែកបម្រើសេវាសមាជិកដើម្បីស្នើសុំ "ការបន្តការថែទាំ" តាមរយៈលេខ **1-833-707-3129** (TTY: **711**) ពីថ្ងៃចន្ទ រហិតដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ។<br><br>ដើម្បីស្វែងយល់ថាតើវេជ្ជបណ្ឌិតរបស់អ្នកស្ថិតក្នុងបណ្តាញរបស់គម្រោងដែរឬទេនោះ សូមហៅទូរសព្ទទៅផ្នែកបម្រើសេវាសមាជិក ឬអាន *សៀវភៅបញ្ជីឈ្មោះអ្នកផ្តល់សេវាកម្ម និងឱសថស្ថាន* របស់ Anthem MediBlue Dual Advantage នៅលើគេហទំព័ររបស់គម្រោងតាមរយៈ [https://shop.anthem.com/medicare/ca](https://shop.anthem.com/medicare/ca)។<br><br>ប្រសិនបើ Anthem MediBlue Full Dual Advantage (HMO D-SNP) គឺថ្មីសម្រាប់អ្នកនោះ យើងនឹងធ្វើការជាមួយអ្នកដើម្បីបង្កើតគម្រោងថែទាំជាលក្ខណៈបុគ្គល ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អ្នក។ |
| **តើអ្វីទៅជាអ្នកសម្របសម្រួលការថែទាំ Anthem MediBlue Full Dual Advantage (HMO D-SNP)?** | អ្នកសម្របសម្រួលការថែទាំ Anthem MediBlue Full Dual Advantage (HMO D-SNP) គឺជាមនុស្សសំខាន់មួយសម្រាប់អ្នកក្នុងការទាក់ទង។ បុគ្គលនេះជួយគ្រប់គ្រងរាល់អ្នកផ្តល់សេវា និងសេវាកម្មរបស់អ្នកទាំងអស់ ហើយធ្វើឱ្យប្រាកដថាអ្នកទទួលបាននូវអ្វីដែលអ្នកត្រូវការ។ |
| **តើសេវាកម្ម និងការគាំទ្ររយៈពេលវែង (LTSS) គឺជាអ្វី?**<br>(បន្តនៅទំព័របន្ទាប់) | សេវាកម្ម និងការគាំទ្ររយៈពេលយូរ គឺជាជំនួយសម្រាប់អ្នកដែលត្រូវការជំនួយដើម្បីធ្វើកិច្ចការប្រចាំថ្ងៃដូចជា ការងូតទឹក ការចូលទៅបង្គន់ ស្លៀកពាក់ ធ្វើម្ហូប និងលេបថ្នាំ។ សេវាកម្មភាគច្រើនត្រូវបានផ្តល់ជូនតាមផ្ទះ ឬនៅតាមសហគមន៍របស់អ្នក ប៉ុន្តែអាចផ្តល់ជូននៅតាមមណ្ឌលថែទាំមនុស្សចាស់ ឬមន្ទីរពេទ្យ។ ក្នុងករណីខ្លះ ខោនធី ឬទីភ្នាក់ងារផ្សេងទៀតអាចគ្រប់គ្រងសេវាកម្មទាំងនេះ ហើយអ្នកសម្របសម្រួលការថែទាំ ឬក្រុមថែទាំរបស់អ្នកនឹងធ្វើការជាមួយទីភ្នាក់ងារនោះ។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| សំណួរដែលគេសួរញឹកញាប់ | ចម្លើយ |
|---|---|
| **តើកម្មវិធីសេវាកម្មជំនួយចម្រុះសម្រាប់មនុស្សចាស់ (MSSP) គឺជាអ្វី?** | MSSP ផ្តល់នូវការសម្របសម្រួលការថែទាំជាបន្តបន្ទាប់ជាមួយអ្នកផ្តល់សេវាថែទាំសុខភាពលើសពីអ្វីដែលគម្រោងសុខភាពរបស់អ្នកផ្តល់រួចហើយ ហើយអាចភ្ជាប់អ្នកទៅកាន់សេវា និងធនធានសហគមន៍ដែលត្រូវការផ្សេងទៀត។ កម្មវិធីនេះជួយអ្នកទទួលបានសេវាកម្មដែលជួយអ្នករស់នៅដោយឯករាជ្យនៅក្នុងផ្ទះរបស់អ្នក។ |
| **តើមានអ្វីកើតឡើងប្រសិនបើខ្ញុំត្រូវការសេវាកម្មមួយ ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងបណ្តាញរបស់ Anthem MediBlue Full Dual Advantage (HMO D-SNP) អាចផ្តល់វាបាន?** | សេវាកម្មភាគច្រើនផ្តល់ជូនដោយអ្នកផ្តល់សេវានៅក្នុងបណ្តាញរបស់យើង។ ប្រសិនបើអ្នកត្រូវការសេវាកម្មដែលមិនអាចត្រូវបានផ្តល់ជូននៅក្នុងបណ្តាញរបស់យើងទេ នោះ Anthem MediBlue Full Dual Advantage នឹងបង់ថ្លៃសម្រាប់ចំណាយលើអ្នកផ្តល់សេវាក្រៅបណ្តាញ។ |
| **តើ Anthem MediBlue Full Dual Advantage (HMO D-SNP) មាននៅឯណា?** | តំបន់សេវាកម្មសម្រាប់គម្រោងនេះរួមមាន៖ ខោនធី Los Angeles និងខោនធី Santa Clara រដ្ឋ California។ អ្នកត្រូវតែរស់នៅក្នុងតំបន់មួយក្នុងចំណោមតំបន់ទាំងនេះ ដើម្បីចូលរួមគម្រោងនេះ។ |
| **តើការអនុញ្ញាតជាមុនជាអ្វី?**<br>(តទៅទំព័របន្ទាប់) | ការអនុញ្ញាតជាមុនមានន័យថា ការយល់ព្រមពី Anthem MediBlue Full Dual Advantage ដើម្បីស្វែងរកសេវានៅក្រៅបណ្តាញរបស់យើង ឬដើម្បីទទួលបានសេវាកម្មដែលជាធម្មតាមិនត្រូវបានធានារ៉ាប់រងដោយបណ្តាញរបស់យើង **មុនពេល**អ្នកទទួលបានសេវាកម្ម។ Anthem MediBlue Full Dual Advantage (HMO D-SNP) ប្រហែលជាមិនធានារ៉ាប់រងលើសេវាកម្ម នីតិវិធី ទំនិញ ឬឱសថទេ ប្រសិនបើអ្នកមិនទទួលបានការអនុញ្ញាតជាមុន។<br><br>**ប្រសិនបើអ្នកត្រូវការការថែទាំបន្ទាន់ ឬសង្គ្រោះបន្ទាន់ ឬសេវាលាងឈាមក្រៅតំបន់ អ្នកមិនចាំបាច់ទទួលបានការអនុញ្ញាតជាមុនជាមុនឡើយ។** Anthem MediBlue Full Dual Advantage អាចផ្តល់ឱ្យអ្នក ឬអ្នកផ្តល់សេវារបស់អ្នកនូវបញ្ជីសេវាកម្ម ឬនីតិវិធីដែលតម្រូវឱ្យអ្នកទទួលបានការអនុញ្ញាតជាមុនពី Anthem MediBlue Full Dual Advantage មុនពេលផ្តល់ជូនសេវាកម្ម។ ប្រសិនបើអ្នកមានសំណួរអំពីថាតើការអនុញ្ញាតជាមុនត្រូវបានទាមទារសម្រាប់សេវាកម្មជាក់លាក់ នីតិវិធី |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| សំណួរដែលគេសួរញឹកញាប់ | ចម្លើយ |
|---|---|
| **តើការអនុញ្ញាតជាមុនជាអ្វី?** (ត) | ទំនិញ ឬឱសថ សូមទូរសព្ទទៅផ្នែកបម្រើសេវាសមាជិកតាមរយៈលេខដែលបានរាយនៅខាងក្រោមទំព័រនេះ ដើម្បីទទួលបានជំនួយ។ |
| **អ្វីទៅជាការបញ្ជូនព្យាបាលបន្ត?** | ការបញ្ជូនបន្តមានន័យថា អ្នកផ្តល់សេវាថែទាំបឋម (PCP) របស់អ្នក ត្រូវតែផ្តល់ឱ្យអ្នកនូវការយល់ព្រមដើម្បីទៅរកនរណាម្នាក់ដែលមិនមែនជា PCP របស់អ្នក។ ការបញ្ជូនបន្តគឺខុសពីការអនុញ្ញាតជាមុន។ ប្រសិនបើអ្នកមិនទទួលបានការបញ្ជូនព្យាបាលបន្តពី PCP របស់អ្នក Anthem MediBlue Full Dual Advantage ប្រហែលជាមិនធានារ៉ាប់រងលើសេវាកម្មនោះទេ។ Anthem MediBlue Full Dual Advantage អាចផ្តល់ឱ្យអ្នកនូវបញ្ជីសេវាកម្មដែលតម្រូវឱ្យអ្នកទទួលបានការបញ្ជូនព្យាបាលបន្តពី PCP របស់អ្នក មុនពេលសេវាកម្មត្រូវបានផ្តល់ជូន។<br><br>សូមអានសៀវភៅណែនាំសមាជិក ដើម្បីយល់ដឹងអំពីការសុំការបញ្ជូនបន្តពី PCP របស់អ្នក។ |
| **តើខ្ញុំបង់ប្រាក់ប្រចាំខែ (ក៏ហៅថាថ្លៃធានារ៉ាប់រងផងដែរ) នៅក្រោម Anthem MediBlue Full Dual Advantage (HMO D-SNP) ដែរឬទេ?** | ទេ។ ដោយសារអ្នកមាន Medi-Cal អ្នកនឹងមិនបង់បុព្វលាភរ៉ាប់រងប្រចាំខែរាប់ទាំងបុព្វលាភរ៉ាប់រងសុខភាព Medicare ផ្នែក B របស់អ្នក សម្រាប់ការធានារ៉ាប់រងសុខភាពរបស់អ្នក។ |
| **តើខ្ញុំបង់ប្រាក់កាត់កងក្នុងនាមជាសមាជិកនៃ Anthem MediBlue Full Dual Advantage (HMO D-SNP) ដែរឬទេ?** | ទេ។ អ្នកមិនបង់ប្រាក់កាត់កងនៅក្នុងAnthem MediBlue Full Dual Advantage (HMO D-SNP) ទេ។ |
| **តើចំនួនប្រាក់ចេញពីហោប៉ៅដែលខ្ញុំនឹងចំណាយសម្រាប់សេវាវេជ្ជសាស្ត្រក្នុងនាមជាសមាជិកនៃ Anthem MediBlue Full Dual Advantage (HMO D-SNP) គឺជាអ្វី?** | មិនមានការចែករំលែកថ្លៃចំណាយសម្រាប់សេវាវេជ្ជសាស្ត្រនៅក្នុង Anthem MediBlue Full Dual Advantage (HMO D-SNP) ដូច្នេះថ្លៃចំណាយចេញពីហោប៉ៅប្រចាំឆ្នាំរបស់អ្នកនឹងមានចំនួន $0។ |

## C. បញ្ជីសេវាដែលបានធានារ៉ាប់រង

តារាងខាងក្រោមគឺជាទិដ្ឋភាពទូទៅខ្លីៗនៃសេវាកម្មអ្វីដែលអ្នកប្រហែលជាត្រូវការ ការចំណាយរបស់អ្នក និងច្បាប់អំពីអត្ថប្រយោជន៍។

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការថែទាំពីមន្ទីរពេទ្យ** | ស្នាក់នៅមន្ទីរពេទ្យ | $0 | គម្រោងរបស់យើងធានារ៉ាប់រងរយៈពេល 90 ថ្ងៃសម្រាប់ការស្នាក់នៅក្នុងមន្ទីរពេទ្យចំពោះអ្នកជំងឺស្នាក់ព្យាបាល។<br>គម្រោងរបស់យើងក៏ធានារ៉ាប់រងរយៈ 60 ថ្ងៃ "បម្រុងទុកពេញមួយជីវិត"។ ទាំងនេះគឺជាថ្ងៃ "បន្ថែម" ដែលយើងធានារ៉ាប់រង។ ប្រសិនបើការស្នាក់នៅមន្ទីរពេទ្យរបស់អ្នកលើសពី 90 ថ្ងៃ អ្នកអាចប្រើថ្ងៃបន្ថែមទាំងនេះបាន។ នៅពេលដែលអ្នកបានប្រើប្រាស់លើសពី 60 ថ្ងៃទាំងនេះ ការធានារ៉ាប់រងក្នុងមន្ទីរពេទ្យចំពោះអ្នកជំងឺស្នាក់ព្យាបាលរបស់អ្នកនឹងត្រូវបានកំណត់ត្រឹម 90 ថ្ងៃ។<br>តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ការថែទាំដោយវេជ្ជបណ្ឌិត ឬគ្រូពេទ្យវះកាត់ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សេវាក្នុងមន្ទីរពេទ្យចំពោះអ្នកជំងឺមិនស្នាក់ព្យាបាល រួមទាំងការអង្កេត | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សេវាកម្មមជ្ឈមណ្ឌលវះកាត់ចល័ត (ASC) | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកចង់បានវេជ្ជបណ្ឌិត** | ជួបដើម្បីព្យាបាលរបួស ឬជំងឺ | $0 | អាចត្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ការថែទាំដោយអ្នកឯកទេស | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ការជួបពនិត្យសុខុមាលភាព ដូចជា ផ្នែករាងកាយ | $0 | |
| | ការថែទាំដើម្បីរក្សាសុខភាពអ្នកពីការឈឺ ដូចជាការចាក់វ៉ាក់សាំងគ្រុនផ្ដាសាយ និងការឆ្លុះពិនិត្យរកមើលជំងឺមហារីក | $0 | |
| | "Medicare សូមស្វាគមន៍" (ការណាត់ជួបដើម្បីបង្ការជំងឺមានតែម្ដងប៉ុណ្ណោះ) | $0 | កំណត់ត្រឹមតែមួយដង។ |
| **អ្នកត្រូវការការថែទាំសង្គ្រោះបន្ទាន់** (បន្តនៅទំព័របន្ទាប់) | សេវាបន្ទប់សង្គ្រោះបន្ទាន់ | $0 | គម្រោងនេះធានារ៉ាប់រងលើសេវាបន្ទប់សង្គ្រោះបន្ទាន់ទាំងក្នុង និងក្រៅបណ្ដាញ ហើយអ្នកមិនចាំបាច់ទទួលបានការបញ្ជូនព្យាបាលបន្ត ឬការអនុញ្ញាតមុនពេលស្វែងរកការថែទាំវេជ្ជសាស្ត្រនោះទេ។ |

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្តីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការការថែទាំសង្គ្រោះបន្ទាន់**<br>(ត) | ការថែទាំព្យាបាលដែលត្រូវការជាបន្ទាន់ | $0 | គម្រោងនេះធានារ៉ាប់រងលើសេវាថែទាំដែលត្រូវការជាបន្ទាន់ ទាំងក្នុង និងក្រៅបណ្តាញ ហើយអ្នកមិនចាំបាច់ទទួលបានការបញ្ជូនបន្ត ឬការអនុញ្ញាតមុនពេលស្វែងរកការថែទាំវេជ្ជសាស្ត្រនោះទេ។ |
| **អ្នកត្រូវការការធ្វើតេស្តវេជ្ជសាស្ត្រ** | សេវាធ្វើរោគវិនិច្ឆ័យដោយកាំរស្មីឆ្លុះ (ឧទាហរណ៍ កាំរស្មីអ៊ិច ឬសេវាកម្មថតរូបភាពផ្សេងទៀតដូចជាការស្កេនដងខ្លួនអ្នកជំងឺដោយប្រើកុំព្យូទ័រ (CAT) ឬបច្ចេកទេសថតរាងកាយដោយប្រើសំឡេងផ្លាតពីដែនទំនាញ (MRI) | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ការធ្វើនីតិវិធីតេស្ត និងរោគវិនិច្ឆ័យនៅក្នុងមន្ទីរពិសោធន៍ដូចជាការពិនិត្យឈាម | $0 | អាចត្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| **អ្នកត្រូវការសេវាកម្មសុខភាពត្រចៀក/សោតវិញ្ញាណ** | ការពិនិត្យសុខភាពត្រចៀក | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ឧបករណ៍ជំនួយការស្តាប់ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។<br>ការធានារ៉ាប់រងបន្ថែមអាចមានតាមរយៈ: Medi-Cal។<br>សូមមើល *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានលម្អិតបន្ថែម ឬទាក់ទងអ្នកសម្របសម្រួលការថែទាំរបស់អ្នកសម្រាប់ជំនួយ។ |

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្តីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការការថែទាំធ្មេញ** (តទៅទំព័របន្ទាប់) | ការពិនិត្យ និងការថែទាំបង្ការសុខភាពធ្មេញ | $0 | អ្នកអាចស្វែងរកព័ត៌មានអំពីអត្ថប្រយោជន៍របស់គម្រោងនេះនៅក្នុង *សៀវភៅណែនាំសមាជិក*របស់អ្នក។ ដើម្បីស្វែងរកទន្តបណ្ឌិតនៅក្នុងតំបន់របស់អ្នកដែលនៅក្នុងបណ្តាញរបស់គម្រោងនៅ៖ https://shop.anthem.com/medicare/ca។<br>ជ្រើសរើស **ឧបករណ៍ដែលមានសារៈសំខាន់ (Useful Tools)** > **ស្វែងរកវេជ្ជបណ្ឌិត (Find a Doctor)** > បញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក > **អ្នកផ្តល់សេវាសុខភាពធ្មេញ (Dental Provider)**<br>អត្ថប្រយោជន៍សុខភាពធ្មេញបន្ថែមអាចរកបានតាមរយៈ Medi-Cal៖ https://www.dhcs.ca.gov/services/Pages/MediCalDental.aspx |
| | ការថែទាំ និងការជួសជុលធ្មេញជាបន្ទាន់ | $0 | គម្រោងនេះរួមបញ្ចូលប្រាក់ឧបត្ថម្ភប្រចាំឆ្នាំចំនួន $1500 សម្រាប់សេវាសុខភាពធ្មេញដ៏ទូលំទូលាយ ដូចជាការដកធ្មេញ និងក្រាសធ្មេញពាក់ជាដើម។<br>អាចតម្រូវឱ្យមានការអនុញ្ញាតជាមុនសម្រាប់ការជួសជុលធ្មេញ។<br>អ្នកអាចស្វែងរកព័ត៌មានអំពីអត្ថប្រយោជន៍របស់គម្រោងនេះនៅក្នុង *សៀវភៅណែនាំសមាជិក*របស់អ្នក។ ដើម្បីស្វែងរកទន្តបណ្ឌិតនៅក្នុងតំបន់របស់អ្នកដែលនៅក្នុងបណ្តាញរបស់គម្រោងនៅ៖ https://shop.anthem.com/medicare/ca។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នក សម្រាប់អ្នកផ្ដល់សេវា នៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការការថែទាំធ្មេញ** (ត) | ការថែទាំសុខភាពធ្មេញលក្ខណៈជួសជុល និងបន្ទាន់ | | ជ្រើសរើស **ឧបករណ៍ដែលមានសារៈសំខាន់ (Useful Tools)** > **ស្វែងរកវេជ្ជបណ្ឌិត (Find a Doctor)** > បញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក > **អ្នកផ្ដល់សេវាសុខភាពធ្មេញ (Dental Provider)**<br>អត្ថប្រយោជន៍សុខភាពធ្មេញបន្ថែមអាចរកបានតាមរយៈ Medi-Cal៖ https://www.dhcs.ca.gov/services/Pages/MediCalDental.aspx |
| **អ្នកត្រូវការការថែទាំភ្នែក** | ការពិនិត្យភ្នែក | $0 | គម្រោងនេះរួមបញ្ចូលការពិនិត្យភ្នែកជាប្រចាំមួយដងជារៀងរាល់ឆ្នាំ។ |
| | វ៉ែនតា ឬកែវដាក់ក្នុងភ្នែក | $0 | គម្រោងនេះរួមបញ្ចូលប្រាក់ឧបត្ថម្ភប្រចាំឆ្នាំចំនួន $300 សម្រាប់វ៉ែនតា និង/ឬកែវដាក់ក្នុងភ្នែក។<br>តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។<br>សូមមើល *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានលម្អិត ឬទាក់ទងអ្នកសម្របសម្រួលការថែទាំរបស់អ្នកសម្រាប់ជំនួយ។<br>ការធានារ៉ាប់រងបន្ថែមអាចមានតាមរយៈ Medi-Cal។ |
| | ការពិនិត្យសុខភាពភ្នែកផ្សេងទៀត | $0 | |

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការសេវាកម្មសុខភាពផ្លូវចិត្ត** | សេវាសុខភាពផ្លូវចិត្ត | $0 | អាចត្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ការថែទាំអ្នកជំងឺស្នាក់ព្យាបាល និងអ្នកជំងឺមិនស្នាក់ព្យាបាល និងសេវាតាមសហគមន៍សម្រាប់អ្នកដែលត្រូវការតំហែទាំសុខភាពផ្លូវចិត្ត | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។<br>សូមមើល *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានលម្អិតបន្ថែម។ |
| **អ្នកត្រូវការសេវាព្យាបាលវិបត្តិនៃការប្រើប្រាស់សារធាតុញៀន** | សេវាព្យាបាលវិបត្តិនៃការប្រើប្រាស់សារធាតុញៀន | $0 | សូមមើល *សៀវភៅណែនាំសមាជិក* របស់អ្នកសម្រាប់ព័ត៌មានលម្អិត។ |
| **អ្នកត្រូវការកន្លែងរស់នៅដែលមានមនុស្សអាចជួយអ្នកបាន** | ការថែទាំពីគិលានុបដ្ឋាកជំនាញ | $0 | គម្រោងនេះធានារ៉ាប់រងរហូតដល់ 100 ថ្ងៃនៅមជ្ឈមណ្ឌលថែទាំសុខភាពដែលមានជំនាញ (SNF)។ |
| | ការថែទាំនៅតាមគេហដ្ឋាន | $0 | សូមមើល *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានលម្អិតបន្ថែម។ |
| | ការមើលថែមនុស្សពេញវ័យ និងការមើលថែក្រុមមនុស្សពេញវ័យ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។<br>សូមមើល *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានលម្អិតបន្ថែម។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្តីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការការព្យាបាលបន្ទាប់ពីមានជំងឺដាច់សរសៃឈាមខួរក្បាល ឬគ្រោះថ្នាក់** | ការព្យាបាលចលនា រាងកាយ ឬការព្យាបាលអ្នកមានបញ្ហានិយាយ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| **អ្នកត្រូវការជំនួយក្នុងការទទួលបានសេវាសុខភាព** | សេវាកម្មរថយន្តសង្គ្រោះបន្ទាន់ | $0 | ការអនុញ្ញាតជាមុនអនុវត្តចំពោះសេវាកម្មដឹកជញ្ជូនតាមរថយន្តសង្គ្រោះបន្ទាន់ដែលមិនស្ថិតក្នុងភាពអាសន្ន។ |
| | មធ្យោបាយដឹកជញ្ជូនសង្គ្រោះបន្ទាន់ | $0 | |
| | មធ្យោបាយធ្វើដំណើរទៅការណាត់ជួបវេជ្ជសាស្ត្រ និងសេវាកម្មនានា | $0 | គម្រោងនេះរួមបញ្ចូលទាំងការធ្វើដំណើរមួយជើងចំនួន 65 ដងដើម្បីរៀបចំគម្រោងទីតាំងដែលបានអនុម័ត។ ការធ្វើដំណើរត្រូវបានកំណត់ត្រឹម 60 ម៉ាយ និងទាមទារការជូនដំណឹងជាមុន 48 ម៉ោង។ ការធានារ៉ាប់រងបន្ថែមមានតាមរយៈ Medi-Cal។ សូមមើល *សៀវភៅណែនាំសមាជិក* របស់អ្នកសម្រាប់ព័ត៌មានលម្អិត។ |
| **អ្នកត្រូវការឱសថដើម្បីព្យាបាលជំងឺរបស់អ្នក ឬស្ថានភាពរបស់អ្នក**<br>(បន្តនៅទំព័របន្ទាប់) | ឱសថមានវេជ្ជបញ្ជារបស់ Medicare ផ្នែក B | $0 | ឱសថផ្នែក B<br>រួមមានឱសថដែលផ្តល់ឱ្យដោយវេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងការិយាល័យរបស់ពួកគេ<br>ឱសថសម្រាប់ជំងឺមហារីកមាត់ និងឱសថមួយចំនួនដែលបានប្រើប្រាស់ជាមួយគ្រឿងបរិក្ខារវេជ្ជសាស្ត្រជាក់លាក់។ សូមអាន *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានបន្ថែមអំពីឱសថទាំងនេះ។<br>តម្រូវឱ្យមានការអនុញ្ញាតជាមុន។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការឱសថដើម្បីព្យាបាលជំងឺរបស់អ្នក ឬស្ថានភាពរបស់អ្នក**<br>(ត) | ឱសថទូទៅ (គ្មានម៉ាកយីហោ) | $0 | អាចនឹងមានកំណត់ចំពោះប្រភេទឱសថដែលស្ថិតក្នុងការធានារ៉ាប់រង។ សូមមើល *បញ្ជីឱសថដែលមានការរ៉ាប់រង* (បញ្ជីឱសថ) របស់ Anthem MediBlue Full Dual Advantage (HMO D-SNP) សម្រាប់ព័ត៌មានបន្ថែម។<br>ការផ្គត់ផ្គង់ថ្ងៃបន្ថែមមាននៅលើវេជ្ជបញ្ជាកម្រិតទី 1 និងកម្រិតទី 6 ក្នុងតម្លៃដូចគ្នា។ |
| | ឱសថមានឈ្មោះម៉ាកយីហោ | $0 | អាចនឹងមានកំណត់ចំពោះប្រភេទឱសថដែលស្ថិតក្នុងការធានារ៉ាប់រង។ សូមមើល *បញ្ជីឱសថដែលមានការរ៉ាប់រង* (បញ្ជីឱសថ) របស់ Anthem MediBlue Full Dual Advantage (HMO D-SNP) សម្រាប់ព័ត៌មានបន្ថែម។<br>ការផ្គត់ផ្គង់ថ្ងៃបន្ថែមមិនមាននៅលើវេជ្ជបញ្ជាមានម៉ាកទេ។ |
| | ឱសថដែលអ្នកអាចទទួលបានដោយគ្មានវេជ្ជបញ្ជា (OTC) | $0 | អាចនឹងមានកំណត់ចំពោះប្រភេទឱសថដែលស្ថិតក្នុងការធានារ៉ាប់រង។ សូមមើល *បញ្ជីឱសថដែលមានការរ៉ាប់រង* (បញ្ជីឱសថ) របស់ Anthem MediBlue Full Dual Advantage (HMO D-SNP) សម្រាប់ព័ត៌មានបន្ថែម។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្តីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការជំនួយឱ្យសុខភាពប្រសើរឡើង ឬមានតម្រូវការសុខភាពពិសេស** | សេវាស្តារនីតិសម្បទា | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សម្ភារវេជ្ជសាស្ត្រសម្រាប់ការថែទាំតាមផ្ទះ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សេវាវះកាត់លាងតម្រងនោម | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| **អ្នកត្រូវការការថែទាំជើង** | សេវាកម្មព្យាបាលជើង | $0 | បន្ថែមពីលើការថែទាំជើងជាប្រចាំ គម្រោងនេះរួមបញ្ចូលការធានារ៉ាប់រងសម្រាប់ការទៅជួបពិគ្រោះជាមួយគ្រូពេទ្យដោយគ្មានដែនកំណត់។ |
| | សេវាកម្មកែទម្រង់ឆ្អឹង | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| **អ្នកត្រូវការឧបករណ៍វេជ្ជសាស្ត្រសម្រាប់ប្រើរយៈពេលវែង (DME)** (តទៅទំព័របន្ទាប់)<br><br>**(ចំណាំ៖** នេះមិនមែនជាបញ្ជីពេញលេញនៃ DME ទេ។ សម្រាប់បញ្ជីពេញលេញ សូមទាក់ទងផ្នែកបម្រើសេវាសមាជិក ឬមើលជំពូកទី 4 នៃ *សៀវភៅណែនាំសមាជិក*)។ | រទេះរុញ ឈើច្រត់ និងឧបករណ៍ជំនួយការដើរ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ឧបករណ៍បាញ់ទឹក | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ឧបករណ៍ និងគ្រឿងផ្គត់ផ្គង់អុកស៊ីសែន | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការជំនួយក្នុងការរស់នៅផ្ទះ**<br>(តទៅទំព័របន្ទាប់) | សេវាកម្មសុខភាពតាមផ្ទះ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សេវាកម្មតាមផ្ទះ ដូចជាការសម្អាត ឬការថែរក្សាគេហដ្ឋាន ឬការកែប្រែគេហដ្ឋាន ដូចជារបារចាប់កាន់<br>សេវាកម្មតាមផ្ទះ ដូចជាការសម្អាត ឬការថែរក្សាគេហដ្ឋាន ឬការកែប្រែគេហដ្ឋាន ដូចជារបារចាប់កាន់ (ត) | $0 | សម្រាប់សេវាកម្មក្នុងផ្ទះ៖ សូមទាក់ទងអ្នកសម្របសម្រួលការថែទាំរបស់អ្នក ដើម្បីទទួលបានព័ត៌មានអំពីរបៀបចូលប្រើសេវាកម្មទាំងនេះ។<br>សម្រាប់ការកែប្រែគេហដ្ឋាន៖ សូមមើល *សៀវភៅណែនាំសមាជិក*របស់អ្នកសម្រាប់ព័ត៌មានលម្អិត។ |
| | សេវាសុខភាពប្រចាំថ្ងៃរបស់មនុស្សពេញវ័យ សេវាកម្មសម្រាប់មនុស្សពេញវ័យនៅតាមសហគមន៍ (CBAS) ឬសេវាកម្មជំនួយផ្សេងទៀត | $0 | សម្រាប់ CBAS និងសេវាសុខភាពប្រចាំថ្ងៃរបស់មនុស្សពេញវ័យ៖ សូមទាក់ទងអ្នកសម្របសម្រួលការថែទាំរបស់អ្នក ដើម្បីទទួលបានព័ត៌មានអំពីរបៀបចូលប្រើសេវាកម្មទាំងនេះ។<br>សម្រាប់សេវាកម្មជំនួយផ្សេងទៀត៖ សូមមើល *សៀវភៅណែនាំសមាជិក*របស់អ្នកសម្រាប់ព័ត៌មានលម្អិត។<br>អាចត្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សេវាស្ដារនីតិសម្បទារប្រចាំថ្ងៃ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។<br>សេវាកម្មទាំងនេះត្រូវបានធានារ៉ាប់រងក្រោម CBAS (ខាងលើ)។<br>សូមមើល *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានលម្អិតបន្ថែម។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **អ្នកត្រូវការជំនួយក្នុងការរស់នៅផ្ទះ**<br>(ត) | សេវាកម្មដើម្បីជួយអ្នករស់នៅដោយខ្លួនឯង (សេវាថែទាំសុខភាពតាមផ្ទះ ឬសេវាអ្នកមើលថែទាំផ្ទាល់ខ្លួន) | $0 | សូមទាក់ទងអ្នកសម្របសម្រួលការថែទាំសុខភាពរបស់អ្នក ដើម្បីទទួលបានព័ត៌មានអំពីរបៀបដាក់ពាក្យសុំ និងចូលប្រើសេវាកម្មទាំងនេះ។<br>អាចត្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។<br>សូមមើល *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានលម្អិតបន្ថែម។ |
| **សេវាកម្មបន្ថែម**<br>(បន្តនៅទំព័របន្ទាប់) | សេវាកម្មចាប់សរសៃ | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ការផ្គត់ផ្គង់ និងសេវាកម្មជំងឺទឹកនោមផ្អែម | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សេវាជំនួសសរីរាង្គដែលកាត់ចោល | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | ការព្យាបាលដោយកាំរស្មី | $0 | តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្ត។ |
| | សេវាកម្មដើម្បីជួយគ្រប់គ្រងជំងឺរបស់អ្នក | $0 | សូមមើល *សៀវភៅណែនាំសមាជិក* របស់អ្នកសម្រាប់ព័ត៌មានលម្អិត។ |
| | ខ្សែទូរសព្ទសេវាគិលានុបដ្ឋាក 24/7 | $0 | អាចទូរសព្ទមកកាន់លេខជំនួយប្រចាំការរបស់គិលានុបដ្ឋាយិកា 24 ម៉ោង 7 ថ្ងៃក្នុងមួយសប្ដាហ៍ 365 ថ្ងៃក្នុងមួយឆ្នាំ៖ **1-855-658-9249**។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **សេវាកម្មបន្ថែម**<br>(ត) | ភាពចាំបាច់បន្ថែមសំខាន់ៗ<br>(ដើម្បីជ្រើសរើសអត្ថប្រយោជន៍ សូមទូរសព្ទទៅផ្នែកបម្រើសេវាសមាជិក ឬមើល *សៀវភៅណែនាំសមាជិក*របស់អ្នកសម្រាប់ការណែនាំ។) | $0 | អ្នកអាចជ្រើសរើសអត្ថប្រយោជន៍ពីរក្នុងចំណោមអត្ថប្រយោជន៍ទាំងនេះក្នុងមួយឆ្នាំប្រតិទិន ដោយមិនគិតថ្លៃបន្ថែម៖<br>• **ឧបករណ៍ជំនួយ**<br>អ្នកអាចទទួលបានប្រាក់ឧបត្ថម្ភប្រចាំឆ្នាំរហូតដល់ $500 សម្រាប់ឧបករណ៍ជំនួយ និងសុវត្ថិភាព ដូចជា បង្កាន់ដៃ កៅអីអង្គុយពេលងូតទឹកផ្កាឈូក បង្គន់មានដៃកាន់ និងផ្លូវសម្រាប់ចល័តបណ្ដោះអាសន្ន។<br>• **គណនី Flex - ធ្មេញ ភ្នែក ត្រចៀក**<br>រីករាយជាមួយការធានារ៉ាប់រងបន្ថែមរហូតដល់ $500 ក្នុងមួយឆ្នាំសម្រាប់តម្រូវការធ្មេញ ភ្នែក ឬត្រចៀករបស់អ្នក។ អ្នកអាចជ្រើសរើសរបៀបចំណាយប្រាក់ឧបត្ថម្ភប្រចាំឆ្នាំរបស់អ្នក ពីថ្លៃចំណាយចេញពីហោប៉ៅ ឬសេវាកម្មបន្ថែម។<br>• **គណនី Flex - ឧបករណ៍ប្រើប្រាស់**<br>អ្នកអាចទទួលបាន $50 ជារៀងរាល់ខែសម្រាប់ការទូទាត់ថ្លៃប្រើប្រាស់ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ រួមមាន ហ្គាស អគ្គិសនី ទឹក លូទឹកស្អុយ អ៊ីនធឺណិត និងសូម្បីតែគម្រោងប្រព័ន្ធទូរសព្ទ។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **សេវាកម្មបន្ថែម**<br>(ត) | ភាពចាំបាច់បន្ថែមសំខាន់ៗ (បន្ត) | | • **គ្រឿងទេសសម្រាប់សុខភាព**<br>សន្សំលើថ្លៃចំណាយលើគ្រឿងទេសសម្រាប់សុខភាព ដែលមានទឹកប្រាក់ $50 ក្នុងមួយខែ ដែលល្អចំពោះការទិញនៅហាងដែលចូលរួមនៅជិតអ្នក។<br>• **ជំនួយនៅក្នុងផ្ទះ**<br>រីករាយជាមួយភាពមានអ្នកនៅជាមួយរហូតដល់ 60 ម៉ោងក្នុងមួយឆ្នាំតាមប្រតិទិន និងសកម្មភាពឯករាជ្យក្នុងការរស់នៅប្រចាំថ្ងៃ ដូចជាការជួយការងារស្រាលក្នុងផ្ទះ ការងារស្រាលក្រៅផ្ទះ ជំនួយផ្នែកបច្ចេកវិទ្យា និងច្រើនទៀត។<br>• **មធ្យោបាយធ្វើដំណើរ**<br>ប្រសិនបើអ្នកត្រូវការជិះទៅកាន់ទីតាំងដែលគម្រោងបានអនុញ្ញាត អត្ថប្រយោជន៍នេះផ្ដល់ឱ្យអ្នកនូវការធ្វើដំណើរមួយជើង 60 ដងក្នុងមួយឆ្នាំ។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្តីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **សេវាកម្មបន្ថែម** (ត) | ការហាត់ប្រាណ | $0 | • **កម្មវិធីហាត់ប្រាណនៅ SilverSneakers®**<br>នៅពេលអ្នកក្លាយជាសមាជិករបស់យើង អ្នកអាចចុះឈ្មោះនៅ SilverSneakers។ វាបានរួមបញ្ចូលទៅក្នុងគម្រោងរបស់យើង។ ដើម្បីស្វែងយល់លម្អិតបន្ថែម សូមចូលទៅកាន់ www.silversneakers.com ឬទូរសព្ទទៅ SilverSneakers តាមរយៈលេខ 1-855-741-4985 (TTY: 711) ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ ម៉ោងនៅភាគខាងកើត។<br>*កម្មវិធីហាត់ប្រាណ SilverSneakers Fitness ត្រូវបានផ្តល់ដោយ Tivity Health ដែលជាក្រុមហ៊ុនឯករាជ្យ។ SilverSneakers និងប្រភេទនិមិត្តសញ្ញាស្បែកជើង SilverSneakers គឺជាពាណិជ្ជសញ្ញាដែលបានចុះបញ្ជីរបស់ Tivity Health, Inc. © 2022 TivityHealth, Inc. រក្សាសិទ្ធគ្រប់យ៉ាង។<br>• **គណនី Flex – ការហាត់ប្រាណដែលសកម្ម**<br>គម្រោងនេះធានារ៉ាប់រងលើប្រាក់ឧបត្ថម្ភ $25 ជារៀងរាល់ខែសម្រាប់ការទូទាត់ថ្លៃចូលប្រើសម្រាប់ថ្នាក់ហាត់ប្រាណ និងថ្នាក់/កម្មវិធីដែលផ្តល់ដោយកន្លែងហាត់ប្រាណនិងកីឡាដូចជាកម្មវិធីវាយកូនហ្គោល អាងហែលទឹក និងទីលានវាយកូនបាល់ ដែលត្រូវបង់ថ្លៃសម្រាប់ការចូលប្រើប្រាស់។ ចំនួនទឹកប្រាក់ផុតកំណត់នៅចុងខែ។ ប្រាក់ដែលមិនបានប្រើប្រាស់នឹងផុតកំណត់នៅចុងឆ្នាំ។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្តីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **សេវាកម្មបន្ថែម** (ត) | ការហាត់ប្រាណ (ត) | | • **កម្មវិធីតាមដានសុខភាព និងកាយសម្បទា** អ្នកអាចរីករាយជាមួយឧបករណ៍តាមដានកាយសម្បទា (ជារៀងរាល់ឆ្នាំ) រួមទាំងការចូលប្រើកម្មវិធីអនឡាញ ដើម្បីជួយអ្នកសម្រេចបាននូវគោលដៅនៃការរស់រវែងសុខភាពផ្លូវចិត្ត និងសុខភាពរបស់អ្នក។ |
| | អាហារសុខភាព (Healthy Meals) | $0 | អ្នកអាចរីករាយជាមួយអាហារដែលមានសុខភាពល្អដែលដឹកជញ្ជូនដោយផ្ទាល់ទៅដល់ផ្ទះរបស់អ្នក។ អ្នកអាចទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ រហូតដល់ 90 ថ្ងៃ ដើម្បីផ្គត់ផ្គង់តម្រូវការអាហារូបត្ថម្ភរបស់អ្នក។ |
| | LiveHealth® Online | $0 | អនុញ្ញាតឱ្យអ្នកនិយាយទៅកាន់វេជ្ជបណ្ឌិតដែលមានវិញ្ញាបនបត្រចេញពីក្រុមប្រឹក្សា ឬគ្រូពេទ្យឯកទេសផ្នែកវិកលចរិត គ្រូពេទ្យចិត្តសាស្រ្ត ឬអ្នកព្យាបាលរោគដែលមានអាជ្ញាបណ្ណ តាមរយៈវីដេអូលើកុំព្យូទ័រ ទូរសព្ទស្មាតហ្វូន ឬថេប្លេតដែលផ្សាយផ្ទាល់ទៅវិញទៅមក។ |
| | ការគាំទ្រធនធានសហគមន៍ Medicare | $0 | យើងជួយអ្នកភ្លាមៗតាមរយៈប្រព័ន្ធទូរសព្ទដោយផ្តល់ឱ្យអ្នកនូវព័ត៌មានដែលទាក់ទងទៅនឹងសុខភាព និងដោយភ្ជាប់អ្នកទៅកាន់សេវាសហគមន៍មូលដ្ឋាន និងកម្មវិធីគាំទ្រ។ យើងនឹងជួយអ្នកក្នុងការសម្របសម្រួលសេវាកម្មទាំងនេះដោយផ្អែកលើតម្រូវការតែមួយគត់របស់អ្នក។ |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្តីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **សេវាកម្មបន្ថែម**<br>(ត) | ការគាំទ្រធនធានសហគមន៍ Medicare<br>(ត) | | ហៅទូរសព្ទមកយើងតាមរយៈលេខដែលបង្ហាញក្នុងបណ្ណសម្គាល់គម្រោងរបស់អ្នក ហើយសួររកក្រុមការងារគាំទ្រធនធានសហគមន៍ Medicare សម្រាប់ព័ត៌មានលម្អិតបន្ថែម។ |
| | ទំនិញគ្មានវេជ្ជបញ្ជា (OTC) | $0 | មានវិធីបីយ៉ាងក្នុងការទទួលបាននូវអត្ថប្រយោជន៍របស់អ្នក៖<br>• ទិញទំនិញតាមអនឡាញ ឬប្រើតាមកម្មវិធី និងផ្ញើទំនិញទៅផ្ទះរបស់អ្នក ឬទៅកាន់ទីតាំងហាងណាដែលនៅជិតអ្នកសម្រាប់ការទៅយកនោះ<br>• ទៅទិញទំនិញនៅក្នុងហាងលក់ទំនិញ Walmart និង Neighborhood Market ចំនួនជាង 4,700 និងតាមកន្លែងលក់រាយផ្សេងទៀតដែលចូលរួម<br>• ហៅទូរសព្ទដើម្បីធ្វើការបញ្ជាទិញ និងផ្ញើទំនិញទៅកាន់ផ្ទះរបស់អ្នក |
| | ប្រព័ន្ធឆ្លើយតបសង្គ្រោះបន្ទាន់ផ្ទាល់ខ្លួន (PERS) ដែលមានការធានារ៉ាប់រង | $0 | រួមបញ្ចូលឧបករណ៍តាមដាន និងសេវាតាមដាន។ សូមធ្វើការហៅទូរសព្ទមកយើង ដើម្បីចាប់ផ្តើម និងដំឡើងសេវាកម្ម។ យើងអាចជួយលោកអ្នក។<br>អាចត្រូវការការអនុញ្ញាតជាមុន។ |

| តម្រូវការ ឬការព្រួយបារម្ភអំពីសុខភាព | សេវាកម្មដែលអ្នកអាចនឹងត្រូវការ | ការចំណាយរបស់អ្នកសម្រាប់អ្នកផ្ដល់សេវានៅក្នុងបណ្ដាញ | ព័ត៌មានអំពីការកំណត់ ការលើកលែង និងអត្ថប្រយោជន៍ (ច្បាប់ស្ដីពីអត្ថប្រយោជន៍) |
|---|---|---|---|
| **សេវាកម្មបន្ថែម**<br>(ត) | ជំនួយសហគមន៍ | $0 | សេវាកម្មរួមមាន៖<br>• សេវាជំនួយលើការស្វែងរកទីលំនៅដែលចង់ផ្លាស់ប្ដូរ<br>• ប្រាក់កក់កន្លែងស្នាក់នៅ<br>• សេវាផ្ដល់ស្ថិរភាពក្នុងការរស់នៅ និងការជួលផ្ទះ<br>• កន្លែងស្នាក់នៅក្រោយចេញពីមន្ទីរពេទ្យក្នុងរយៈពេលខ្លី (STPH)<br>• ការថែទាំឱ្យជាសះស្បើយឡើងវិញ (ការសម្រាកព្យាបាលបណ្ដោះអាសន្ន)<br>• សេវាថែទាំបណ្ដោះអាសន្ន<br>• ការស្ដារនិតិសម្បទាប្រចាំថ្ងៃ<br>• ការផ្លាស់ប្ដូរមជ្ឈមណ្ឌលថែទាំ/ការផ្លាស់ប្ដូរទៅមជ្ឈមណ្ឌលជំនួយក្នុងការរស់នៅ<br>• សេវាការផ្លាស់ប្ដូរចូលក្នុងសហគមន៍/ការផ្លាស់ប្ដូរពីមជ្ឈមណ្ឌលថែទាំទៅកាន់គេហដ្ឋាន<br>• សេវាថែទាំផ្ទាល់ខ្លួន និងសេវាមេផ្ទះ<br>• ការសម្របសម្រួលបរិស្ថានរស់នៅ (ការកែប្រែបរិស្ថានក្នុងផ្ទះ)<br>• អាហារ/អាហារសម្រន់តាមវេជ្ជសាស្ត្រ<br>• មណ្ឌលផ្ដាច់គ្រឿងស្រវឹងរយៈពេលខ្លី |

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

សេចក្ដីសង្ខេបនៃអត្ថប្រយោជន៍នេះត្រូវបានផ្ដល់ជូនសម្រាប់គោលបំណងផ្ដល់ជាព័ត៌មានតែមួយមុខប៉ុណ្ណោះ ហើយវាមិនមែនជាបញ្ជីពេញលេញនៃអត្ថប្រយោជន៍នោះទេ។ សម្រាប់បញ្ជីពេញលេញ និងព័ត៌មានច្រើនទៀតអំពីអត្ថប្រយោជន៍ អ្នកអាចអាន *សៀវភៅណែនាំសមាជិក*របស់ Anthem MediBlue Full Dual Advantage (HMO D-SNP)។ ប្រសិនបើអ្នកមិនមាន *សៀវភៅណែនាំសមាជិក*ទេនោះ សូមទូរសព្ទទៅផ្នែកបម្រើសេវាបម្រើសមាជិករបស់គម្រោង Anthem MediBlue Full Dual Advantage (HMO D-SNP) តាមរយៈលេខដែលបានបង្ហាញនៅខាងក្រោមនៃទំព័រនេះដើម្បីទទួលបានសៀវភៅមួយក្បាល។ ប្រសិនបើអ្នកមានសំណួរ អ្នកក៏អាចទូរសព្ទទៅកាន់ផ្នែកបម្រើសេវាសមាជិក ឬចូលទៅកាន់គេហទំព័រនៅ https://shop.anthem.com/medicare/ca ។

## D. អត្ថប្រយោជន៍ដែលត្រូវបានធានារ៉ាប់រងពីខាងក្រៅគម្រោង Anthem MediBlue Full Dual Advantage (HMO D-SNP)

មានសេវាកម្មមួយចំនួនដែលអ្នកអាចទទួលបាន ដែលមិនត្រូវបានរ៉ាប់រងដោយ Anthem MediBlue Full Dual Advantage (HMO D-SNP) នោះទេ ប៉ុន្តែវាត្រូវបានរ៉ាប់រងដោយ Medicare, Medi-Cal ឬទីភ្នាក់ងាររដ្ឋ ឬខោនធីជំនួសវិញ ។ នេះមិនមែនជាបញ្ជីពេញលេញនោះទេ។ ហៅទូរសព្ទទៅកាន់ផ្នែកបម្រើសេវាសមាជិក តាមរយៈលេខដែលបានបង្ហាញនៅខាងក្រោមទំព័រនេះ ដើម្បីស្វែងយល់អំពីសេវាកម្មទាំងនេះ។

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| **សេវាកម្មផ្សេងទៀតដែលរ៉ាប់រងដោយ Medicare, MassHealth ឬទីភ្នាក់ងាររដ្ឋ** | **ថ្លៃចំណាយរបស់អ្នក** |
|---|---|
| • កម្មវិធីសុខភាពធ្មេញរបស់ Medi-Call (Smile California \| កម្មវិធីសុខភាពធ្មេញរបស់ Medi-Cal)<br>• សេវាគាំទ្រនៅតាមផ្ទះ៖<br>• សេវាសុខភាពផ្លូវចិត្តពិសេស និងសេវាព្យាបាលការប្រើប្រាស់សារធាតុញៀន<br>• កម្មវិធីលើកលែងរួមទាំងកម្មវិធីលើកលែងដល់ការរស់នៅក្រោមជំនួយ និងកម្មវិធីសេវាជំនួយចម្រុះសម្រាប់មនុស្សចាស់ និងសេវាមជ្ឈមណ្ឌលក្នុងតំបន់<br>សូមទាក់ទងអ្នកសម្របសម្រួលការថែទាំសុខភាពរបស់អ្នក ដើម្បីទទួលបាននូវព័ត៌មានអំពីសិទ្ធិទទួលបាន និងរបៀបចូលប្រើសេវាកម្មទាំងនេះ។ | $0 |
| សេវាថែទាំពីមន្ទីរព្យាបាលអ្នកជំងឺដំណាក់កាលចុងក្រោយដាក់លាក់ដែលត្រូវបានធានារ៉ាប់រងនៅក្រៅគម្រោង Anthem MediBlue Full Dual Advantage (HMO D-SNP) | $0 |
| ការស្តារនីតិសម្បទាផ្នែកផ្លូវចិត្តសង្គម | $0 |
| ការកំណត់គោលដៅគ្រប់គ្រងករណី | $0 |
| បន្ទប់ស្នាក់នៅ និងម្ហូបអាហារ | $0 |

## E. សេវាដែល Anthem MediBlue Full Dual Advantage (HMO D-SNP), Medicare និង Medi-Cal មិនធានារ៉ាប់រងលើ

នេះមិនមែនជាបញ្ជីពេញលេញទេ។ ហៅទូរសព្ទទៅផ្នែកបម្រើសេវាសមាជិកតាមរយៈលេខដែលបានបង្ហាញនៅខាងក្រោមទំព័រនេះ ឬសូមមើល *សៀវភៅណែនាំសមាជិក* របស់អ្នក ដើម្បីស្វែងយល់អំពីសេវាកម្មដែលមិនរាប់បញ្ចូលផ្សេងទៀត។

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

| សេវាដែល Anthem MediBlue Full Dual Advantage (HMO D-SNP), Medicare និង Medi-Cal រ៉ាប់រងលើ |
| --- |
| សេវាដែលមិនត្រូវបានចាត់ទុកថា "សមហេតុផល និងចាំបាច់" យោងទៅតាមស្តង់ដារនៃ Medicare និង Medi-Cal |
| សេវាវេជ្ជសាស្ត្រផ្នែកពិសោធន៍ និងការព្យាបាលដោយការវះកាត់ ទំនិញ និងឱសថ លើកលែងតែត្រូវបានរ៉ាប់រងដោយកម្មវិធី Medicare ឬនៅក្រោមលទ្ធផលសិក្សាស្រាវជ្រាវផ្នែកព្យាបាលដែលត្រូវបានយល់ព្រមដោយកម្មវិធី Medicare |
| ការព្យាបាលដោយការវះកាត់សម្រាប់ជំងឺធាត់លើសទម្ងន់ លើកលែងតែករណីចាំបាច់ផ្នែកវេជ្ជសាស្ត្រ |
| នីតិវិធីលើកកម្ពស់ការជ្រើសរើស ឬស្ម័គ្រចិត្តទទួលការព្យាបាល |
| ការវះកាត់កែសម្ផស្ស ឬការងារកែសម្ផស្សផ្សេងទៀត លុះត្រាតែមានលក្ខខណ្ឌតម្រូវ |
| ការវះកាត់ LASIK |

## F. សិទ្ធិរបស់អ្នកជាសមាជិកនៃគម្រោងនេ

ក្នុងនាមជាសមាជិករបស់ Anthem MediBlue Full Dual Advantage (HMO D-SNP) អ្នកមានសិទ្ធិជាក់លាក់មួយចំនួន។ អ្នកអាចប្រើសិទ្ធិទាំងនេះដោយមិនមានការពិន័យ។ អ្នកក៏អាចប្រើសិទ្ធិទាំងនេះដោយមិនបាត់បង់សេវាថែទាំសុខភាពរបស់អ្នកផងដែរ។ យើងនឹងប្រាប់អ្នកអំពីសិទ្ធិរបស់អ្នកយ៉ាងតិចម្តងក្នុងមួយឆ្នាំ។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកសូមអាន *សៀវភៅណែនាំសមាជិក*។ សិទ្ធិរបស់អ្នករាប់បញ្ចូល ប៉ុន្តែមិនកំណត់ដូចខាងក្រោម៖

- **លោកអ្នកមានសិទ្ធិ ក្នុងការគោរព ភាពត្រឹមត្រូវយុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ។** នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖
  - ទទួលបានសេវា ដែលមានការរ៉ាប់រងដោយគ្មានការព្រួយបារម្ភអំពីស្ថានភាពផ្នែកវេជ្ជសាស្ត្រ ស្ថានភាពសុខភាព ការទទួលសេវាសុខភាព បទពិសោធន៍លើការទាមទារសំណង ប្រវត្តិនៃការព្យាបាល ពិការភាព (រួមទាំងពិការភាពផ្លូវចិត្ត) ស្ថានភាពអាពាហ៍ពិពាហ៍ អាយុ ភេទ (រាប់បញ្ចូលទាំងការនិយមផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ) ចំណូលចិត្តផ្លូវភេទ ដើមកំណើតជាតិ ពូជសាសន៍ ពណ៌សម្បុរ សាសនា ជំនឿ ឬជំនួយសាធារណៈ។
  - ទទួលបានព័ត៌មានជាភាសា និងទម្រង់ផ្សេងទៀត (ឧទាហរណ៍បោះពុម្ពជាអក្សរធំៗ អក្សរស្ទាប ឬជាសំឡេង) ដោយមិនត្រូវបានគិតថ្លៃ
  - មានសេរីភាពពីគ្រប់ទម្រង់នៃការឃាត់ខ្លួន ឬការនៅស្ងៀមោ

- **អ្នកមានសិទ្ធិទទួលព័ត៌មានអំពីការថែទាំសុខភាពរបស់អ្នក។** នេះរួមបញ្ចូលទាំងព័ត៌មានអំពីការព្យាបាល និងជម្រើសនៃការព្យាបាលរបស់អ្នក។ ព័ត៌មានេះគួរតែស្ថិតក្នុងទម្រង់ និងភាសាដែលអ្នកអាចយល់បាន។ នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលបានព័ត៌មាននៅលើ៖
  - ការពិពណ៌នាអំពីសេវានានាដែលយើងបានរ៉ាប់រង
  - របៀបទទួលបានសេវាកម្ម
  - តម្លៃដែលអ្នកត្រូវចំណាយលើសេវាកម្ម
  - ឈ្មោះអ្នកផ្តល់សេវាថែទាំសុខភាព
- **អ្នកមានសិទ្ធិធ្វើការសម្រេចចិត្តអំពីការថែទាំរបស់អ្នករួមទាំងការបដិសេធការព្យាបាល។** នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖
  - សូមជ្រើសរើសអ្នកផ្តល់សេវាថែទាំបឋម (PCP) ហើយអ្នកអាចផ្លាស់ប្តូរ PCP របស់អ្នកនៅពេលណាមួយក៏បានក្នុងឆ្នាំ
  - ជួបអ្នកផ្តល់សេវាថែទាំសុខភាពស្ត្រីដោយមិនបាច់មានការបញ្ជូនបន្ត
  - ទទួលបានសេវាកម្មនិងឱសថដែលមានការគ្របដណ្តប់យ៉ាងរហ័ស
  - ដឹងពីជម្រើសនៃការព្យាបាលទាំងអស់មិនថាពួកគេចំណាយប្រាក់អស់ប៉ុន្មានឬមិនថាពួកគេត្រូវបានគ្របដណ្តប់ឬក៏អត់
  - បដិសេធការព្យាបាល បើទោះបីជាអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកផ្តល់យោបល់ជំទាស់នឹងការបដិសេធនេះក៏ដោយ
  - ឈប់ប្រើឱសថនេះ បើទោះបីជាអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកផ្តល់យោបល់ជំទាស់នឹងការបញ្ឈប់នេះក៏ដោយ
  - សួររកយោបល់ទីពីរ។ Anthem MediBlue Full Dual Advantage (HMO D-SNP) នឹងបង់ថ្លៃចំណាយសម្រាប់ថ្លៃជួបសួររកមតិយោបល់ទីពីររបស់អ្នក
  - ធ្វើឱ្យគេបានដឹងអំពីសេចក្តីប្រាថ្នានៃការថែទាំសុខភាពរបស់អ្នកនៅក្នុងការបង្គាប់បញ្ជាទុកជាមុន
- **អ្នកមានសិទ្ធិក្នុងការទទួលបានការថែរក្សាទាន់ពេលវេលាដោយមិនមានឧបសគ្គក្នុងការប្រាស្រ័យទាក់ទងឬឧបសគ្គខាងរូបកាយ។** នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖
  - ទទួលបានការថែទាំទាន់ពេលវេលា
  - ចេញចូលការិយាល័យរបស់អ្នកផ្តល់សេវាថែទាំសុខភាព។ នេះមានន័យថា ការចូលប្រើដោយគ្មានឧបសគ្គសម្រាប់ជនពិការស្របតាមច្បាប់ស្តីអំពីជនពិការអាមេរិក
  - មានអ្នកបកប្រែដើម្បីជួយទាក់ទងជាមួយអ្នកផ្តល់សេវាថែទាំសុខភាព និងគម្រោងសុខភាពរបស់អ្នក
- **អ្នកមានសិទ្ធិស្វែងរកការថែទាំបន្ទាន់និងពេលមានអាសន្ននៅពេលអ្នកត្រូវការវា។** នេះមានន័យថាអ្នកមានសិទ្ធិ៖
  - ទទួលបានសេវាថែទាំក្នុងគ្រាអាសន្នដោយមិនមានការអនុញ្ញាតទុកជាមុននៅក្នុងគ្រាអាសន្ននោះឡើយ
  - ប្រើប្រាស់អ្នកផ្តល់សេវាថែទាំសុខភាពក្រៅបណ្តាញក្នុងពេលបន្ទាន់ ឬមានអាសន្ន នៅពេលចាំបាច់

- **អ្នកមានសិទ្ធិទទួលបានការរក្សាការសម្ងាត់និងភាពឯកជន។** នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖
  - ស្នើសុំច្បាប់ចម្លងនៃកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នកតាមវិធីដែលអ្នកអាចយល់បាន និងស្នើសុំកែប្រែ ឬផ្លាស់ប្តូរកំណត់ត្រារបស់អ្នក
  - រក្សាព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នកជាឯកជន
- **អ្នកមានសិទ្ធិធ្វើបណ្តឹងអំពីសេវាកម្ម ឬការថែទាំដែលមានការធានារ៉ាប់រងរបស់អ្នក។** នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖
  - ដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងសាទុក្ខប្រឆាំងនឹងយើងខ្ញុំ ឬអ្នកផ្តល់សេវារបស់យើង
  - ដាក់ពាក្យបណ្តឹងជាមួយក្រសួងថែទាំសុខភាពក្រោមការគ្រប់គ្រង (DMHC) នៃរដ្ឋ California តាមរយៈលេខទូរសព្ទដោយឥតគិតថ្លៃ (1-888-466-2219) ឬបណ្តាញទូរសព្ទ TDD (1-877-688-9891) សម្រាប់អ្នកខ្សោយការស្តាប់ និងការនិយាយ។ គេហទំព័រ DMHC ([www.dmhc.ca.gov](http://www.dmhc.ca.gov)) មានទម្រង់ពាក្យបណ្តឹង ទម្រង់ពាក្យស្នើសុំពិនិត្យវេជ្ជសាស្ត្រឯករាជ្យ (IMR) និងការណែនាំដែលមាននៅលើអនឡាញ។
  - ស្នើទៅ DMHC ដើម្បីសុំ IMR នៃសេវាកម្មរបស់ Medi-Cal ឬទំនិញ ជាប្រភេទដែលមានលក្ខណៈវេជ្ជសាស្ត្រ
  - បណ្តឹងឧទ្ធរណ៍លើការសម្រេចចិត្តមួយចំនួន ដែលធ្វើឡើងដោយ DMHC ឬអ្នកផ្តល់សេវារបស់យើង
  - ស្នើសុំសវនាការថ្នាក់រដ្ឋ
  - ទទួលបានហេតុផលលំអិតអំពីមូលហេតុដែលសេវាកម្មត្រូវបានបដិសេធ

សម្រាប់ពត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នក អ្នកអាចចូលទៅអានក្នុង សៀវភៅណែនាំសមាជិកបាន។ ប្រសិនបើអ្នកមានសំណួរ អ្នកអាចទូរសព្ទទៅកាន់ផ្នែកបម្រើសេវាសមាជិករបស់ Anthem MediBlue Full Dual Advantage (HMO D-SNP) តាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។

អ្នកក៏អាចទូរសព្ទហៅទៅកាន់ការិយាល័យមន្ត្រីបណ្តឹងសាធារណៈពិសេសសម្រាប់អ្នកដែលមាន Medicare និង Medi-Cal តាមរយៈលេខ 1-855-501-3077 ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ចន្លោះម៉ោង 9:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច ឬការិយាល័យមន្ត្រីបណ្តឹងសាធារណៈរបស់ Medi-Cal 1-888-452-8609 ពីថ្ងៃចន្ទ រហូតដល់ថ្ងៃសុក្រ ចន្លោះម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច។

## G. របៀបនៃការដាក់ពាក្យបណ្តឹងតវ៉ា ឬប្តឹងឧទ្ធរណ៍លើសេវាកម្មដែលបានបដិសេធ

ប្រសិនបើអ្នកមានបណ្តឹងតវ៉ា ឬគិតថា Anthem MediBlue Full Dual Advantage (HMO D-SNP) គួរតែធានារ៉ាប់រងទៅលើអ្វីមួយដែលយើងបានបដិសេធ សូមទូរសព្ទទៅផ្នែកបម្រើសេវាសមាជិកតាមរយៈលេខដែលរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។ អ្នកអាចប្តឹងឧទ្ធរណ៍លើការសម្រេចចិត្តរបស់យើងបាន។

សម្រាប់ចម្ងល់អំពីបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍ អ្នកអាចអានជំពូកទី 9 នៃ *សៀវភៅណែនាំសមាជិក*។ អ្នកក៏អាចទូរសព្ទទៅផ្នែកបម្រើសេវាសមាជិករបស់ Anthem MediBlue Full Dual Advantage (HMO D-SNP) តាមរយៈលេខដែលរាយនៅផ្នែកខាងក្រោមបំផុតនៃទំព័រនេះ។

អ្នកអាចបញ្ជូនបណ្តឹងតវ៉ា និងបណ្តឹងសារទុក្ខជាលាយលក្ខណ៍អក្សរ។

ផ្ញើសំបុត្រទៅកាន់៖

Anthem MediBlue Full Dual Advantage (HMO D-SNP)
Attn: Complaints, Appeals and Grievances
4361 Irwin Simpson Road
កន្លែងទទួលសំបុត្រ: OH0205-A537
Mason, OH 45040

អ្នកអាចស្នើសុំការពិនិត្យវេជ្ជសាស្ត្រសារឡើងវិញដោយឯករាជ្យ (IMR) ពី ក្រសួងថែទាំសុខភាពដែលគ្រប់គ្រងរដ្ឋ California (DMHC)។ IMR ផ្តល់ជូនសេវារ៉ាប់រង Medi-Cal ឬសម្ភារដែលមានលក្ខណៈវេជ្ជសាស្ត្រ។ IMR គឺជាការពិនិត្យករណីរបស់អ្នកឡើងវិញដោយវេជ្ជបណ្ឌិតដែលមិនស្ថិតក្នុងផ្នែកនៃគម្រោងរបស់យើងខ្ញុំទេ។ បើ IMR ត្រូវសម្រេចតាមសំណើរបស់អ្នក យើងខ្ញុំត្រូវតែផ្តល់ជូនអ្នកនូវសេវាកម្ម ឬសម្ភារៈដែលអ្នកបានស្នើ។ អ្នកមិនត្រូវបង់ថ្លៃចំណាយសម្រាប់ IMR ទេ។

ក្នុងករណីភាគច្រើនអ្នកត្រូវដាក់បណ្តឹងឧទ្ធរណ៍មួយជាមួយយើងមុនពេលស្នើសុំ IMR។ អ្នកត្រូវដាក់ពាក្យសុំ IMR ក្នុងរវាង 6 ខែបន្ទាប់ពីយើងខ្ញុំបានផ្ញើការសម្រេចចិត្តជាលាយលក្ខណ៍អក្សរអំពីបណ្តឹងឧទ្ធរណ៍របស់អ្នក។ DMHC អាចទទួលយកការដាក់ពាក្យសុំបន្ទាប់ពីរយៈពេល 6 ខែ ដោយមានហេតុផលសមរម្យដូចជា អ្នកមានស្ថានភាពសុខភាព ដែលរារាំងអ្នកពីស្នើសុំ IMR សម្រាប់រយៈពេល 6 ខែ ឬ អ្នកមិនបានទទួលការជូនដំណឹងមុនគ្រប់គ្រាន់ពីយើងអំពីដំណើរការ IMR។

ដើម្បីស្នើសុំ IMR៖

- បំពេញពាក្យស្នើសុំការពិនិត្យផ្នែកវេជ្ជសាស្ត្រឯករាជ្យ/ទម្រង់ពាក្យបណ្តឹងតវ៉ាមាននៅ៖ www.dmhc.ca.gov/fileacomplaint/submitanindependentmedicalreviewcomplaintform.aspx ឬទូរសព្ទទៅមជ្ឈមណ្ឌលជំនួយ DMHC តាមរយៈលេខ 1-888-466-2219។ អ្នកប្រើប្រាស់ TTY គួរតែទូរសព្ទទៅកាន់លេខ 1-877-688-9891 ។
- ប្រសិនបើអ្នកមាន សូមភ្ជាប់ជាមួយនូវច្បាប់ចម្លងនៃលិខិត ឬឯកសារផ្សេងទៀត អំពីសេវាកម្ម ឬទំនិញដែលយើងបានបដិសេធ។ វាអាចជួយបង្កើនល្បឿនដំណើរការ IMR បាន។ សូមផ្ញើឯកសារជាច្បាប់ចម្លង មិនមែនច្បាប់ដើមទេ។ មជ្ឈមណ្ឌលផ្តល់ជំនួយមិនអាចប្រគល់ឯកសារណាមួយ ត្រឡប់ទៅវិញទេ។
- បំពេញសំណុំបែបបទជំនួយការដែលបានអនុញ្ញាត ប្រសិនបើមាននរណាម្នាក់កំពុងជួយអ្នកស្នើសុំ IMR របស់អ្នក។ អ្នកអាចទទួលបានទម្រង់បែបបទនេះតាមរយៈ៖

www.dmhc.ca.gov/Portals/0/Docs/HC/AccessibleAAFormEnglish%20%285SG%29.pdf។
ឬទូរសព្ទទៅមជ្ឈមណ្ឌលជំនួយរបស់ក្រសួងតាមរយៈ 1-888-466-2219 ។ អ្នកប្រើប្រាស់ TTY គួរតែទូរសព្ទទៅកាន់លេខ 1-877-688-9891 ។

- ផ្ញើសំបុត្រ ឬទូរសារនូវទម្រង់បែបបទនិងឯកសារភ្ជាប់ណាមួយរបស់អ្នកទៅកាន់៖

  Help Center
  Department of Managed Health Care
  980 9th Street, Suite 500
  Sacramento, CA 95814-2725
  ទូរសារ៖ 1-916-255-5241

## H. តើអ្នកត្រូវធ្វើអ្វីប្រសិនបើអ្នកសង្ស័យថាមានការក្លែងបន្លំ

អ្នកជំនាញ និងអង្គការថែទាំសុខភាពភាគច្រើនដែលផ្ដល់សេវាគឺមានភាពស្មោះត្រង់។ ជាអកុសល ប្រហែលជាមានអ្នកខ្លះដែលមិនស្មោះត្រង់។

ប្រសិនបើអ្នកគិតថាគ្រូពេទ្យ មន្ទីរពេទ្យ ឬឱសថស្ថានផ្សេងទៀតកំពុងធ្វើអ្វីដែលខុសនោះ សូមទាក់ទងមកយើងខ្ញុំ។

- ទូរសព្ទមកយើងខ្ញុំតាមរយៈផ្នែកបម្រើសេវាសមាជិករបស់ Anthem MediBlue Full Dual Advantage (HMO D-SNP)។ លេខទូរសព្ទបានវាយនៅខាងក្រោមទំព័រនេះ។
- ឬទូរសព្ទទៅមជ្ឈមណ្ឌលបម្រើសេវាកម្មអតិថិជន Medi-Cal តាមរយៈ 1-800-841-2900 ។ អ្នកប្រើប្រាស់ TTY អាចហៅទូរសព្ទ 1-800-497-4648 ។
- ឬទូរសព្ទទៅ Medicare តាមរយៈលេខ 1-800-MEDICARE (1-800-633-4227)។ អ្នកប្រើប្រាស់ TTY អាចទូរសព្ទទៅលេខ 1-877-486-2048។ អ្នកអាចទូរសព្ទលេខទាំងនេះដោយឥតគិតថ្លៃ 24 ម៉ោងក្នុងមួយថ្ងៃនិង 7 ថ្ងៃក្នុងមួយសប្ដាហ៍។ ការហៅទូរសព្ទទៅលេខនេះគឺមិនគិតថ្លៃទេ។
- ឬហៅទូរសព្ទទៅបណ្ដាញទូរសព្ទទាន់ហេតុការណ៍នៃផ្នែកក្លែងបន្លំ និងការរំលោភបំពានរបស់ក្រសួងសេវាថែទាំសុខភាពរដ្ឋ California តាមរយៈលេខ 1-800-822-6222។
- ឬទូរសព្ទទៅការិយាល័យយុត្តិធម៌នៃការិយាល័យអគ្គរដ្ឋអាជ្ញានៃការក្លែងបន្លំរបស់ Medi-Cal និងការរំលោភបំពានលើមនុស្សចាស់តាមរយៈ 1-800-722-0432 ។ ការហៅទូរសព្ទរបស់អ្នកគឺឥតគិតថ្លៃ និងជាការសម្ងាត់។

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្ដីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

**ប្រសិនបើអ្នកមានសំណួរទូទៅ ឬសំណួរស្ដីពីគម្រោងរបស់យើង សេវាកម្ម តំបន់សេវាកម្ម វិក្កយបត្រ ឬបណ្ណសមាជិក សូមទូរសព្ទទៅផ្នែកបម្រើសេវាសមាជិករបស់ Anthem MediBlue Full Dual Advantage (HMO D-SNP)៖**

**ទូរសព្ទទៅលេខ៖ 1-833-707-3129**

ការហៅទូរសព្ទទៅកាន់លេខនេះគឺឥតគិតថ្លៃ។ ពីម៉ោង 8 ព្រឹក ដល់ ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍ (លើកលែងតែថ្ងៃបុណ្យ លែងអំណរគុណ និងបុណ្យណូអែល) ចាប់ពីថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែមីនា និងថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (លើកលែងតែថ្ងៃឈប់សម្រាក) ចាប់ពីថ្ងៃទី 1 ខែមេសា ដល់ថ្ងៃទី 30 ខែកញ្ញា។

ផ្នែកសេវាសមាជិកក៏មានអ្នកបកប្រែភាសាដោយឥតគិតថ្លៃសម្រាប់អ្នកដែលមិននិយាយភាសាអង់គ្លេស។

**TTY: 711**

លេខទូរសព្ទនេះត្រូវការឧបករណ៍ទូរសព្ទពិសេស ហើយសម្រាប់តែអ្នកដែលពិបាកក្នុងការស្ដាប់ ឬការនិយាយតែប៉ុណ្ណោះ។

ការហៅទូរសព្ទទៅកាន់លេខនេះគឺឥតគិតថ្លៃ។ ពីម៉ោង 8 ព្រឹក ដល់ ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍ (លើកលែងតែថ្ងៃបុណ្យ លែងអំណរគុណ និងបុណ្យណូអែល) ចាប់ពីថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែមីនា និងថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (លើកលែងតែថ្ងៃឈប់សម្រាក) ចាប់ពីថ្ងៃទី 1 ខែមេសា ដល់ថ្ងៃទី 30 ខែកញ្ញា។

**ប្រសិនបើអ្នកមានសំណួរអំពីសុខភាពរបស់អ្នក៖**

- សូមហៅទូរសព្ទទៅកាន់អ្នកផ្ដល់សេវាថែទាំបឋម (PCP) របស់អ្នក។ អនុវត្តតាមការណែនាំពី PCP របស់អ្នកសម្រាប់ការថែទាំនៅពេលផុតម៉ោងធ្វើការក្នុងការិយាល័យ។
- ប្រសិនបើការិយាល័យ PCP របស់អ្នកត្រូវដល់ម៉ោងបិទនោះ អ្នកក៏អាចទូរសព្ទទៅបណ្ដាញគិលានុបដ្ឋាយកា 24/7 របស់ Anthem MediBlue Dual Advantage បានផងដែរ។ គិលានុបដ្ឋាយិកាម្នាក់នឹងស្ដាប់បញ្ហារបស់អ្នក និងប្រាប់អ្នកពីរបៀបទទួលបានការថែទាំ។ លេខសម្រាប់បណ្ដាញគិលានុបដ្ឋាយកា 24/7 គឺ៖ **1-855-658-9249** (TTY: **711**)។ ការហៅទូរសព្ទទៅកាន់លេខនេះគឺឥតគិតថ្លៃ ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍ 365 ថ្ងៃក្នុងមួយឆ្នាំ។

Anthem MediBlue Full Dual Advantage (HMO D-SNP) ក៏មានសេវាអ្នកបកប្រែភាសាផ្ទាល់មាត់ដោយឥតគិតថ្លៃសម្រាប់អ្នកមិននិយាយភាសាអង់គ្លេសផងដែរ។

ទូរសព្ទទៅលេខ **1-833-707-3129** (TTY: **711**) ពីម៉ោង 8 ព្រឹក ដល់ ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍ (លើកលែងតែថ្ងៃបុណ្យ លែងអំណរគុណ និងបុណ្យណូអែល) ចាប់ពីថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែមីនា និងថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (លើកលែងតែថ្ងៃឈប់សម្រាក) ចាប់ពីថ្ងៃទី 1 ខែមេសា ដល់ថ្ងៃទី 30 ខែកញ្ញា។ ការហៅទូរសព្ទទៅកាន់លេខនេះគឺឥតគិតថ្លៃ។

# Anthem MediBlue Full Dual Advantage (HMO D-SNP) | សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ឆ្នាំ 2023

**ប្រសិនបើអ្នកត្រូវការការថែទាំសុខភាពអាកប្បកិរិយាជាបន្ទាន់ សូមទូរសព្ទទៅលេខបណ្តាញទូរសព្ទសម្រាប់វិបត្តិសុខភាពអាកប្បកិរិយា៖**

- ខោនធី Los Angeles៖ **1-800-854-7771**, (TTY: **711**)
- ខោនធី Santa Clara៖**1-855-278-4204**, (TTY: **711**)

ការហៅទូរសព្ទទៅកាន់លេខទាំងនេះគឺឥតគិតថ្លៃ។ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍រួមទាំងថ្ងៃឈប់សម្រាក។

Anthem MediBlue Full Dual Advantage (HMO D-SNP) ក៏មានសេវាអ្នកបកប្រែភាសាផ្ទាល់មាត់ដោយឥតគិតថ្លៃសម្រាប់អ្នកមិននិយាយភាសាអង់គ្លេសផងដែរ។